# ជំងឺរបេង
## អ្វីដែលអ្នកត្រូវដឹង

Tacoma-Pierce County Health Department
*Healthy People in Healthy Communities*

### ជំងឺរបេង(TB)គឺជាការបង្ករោគដោយបាក់តេរី។



មនុស្សភាគច្រើនដែលមានជំងឺរបេង គឺមានរោគនេះនៅក្នុងសួតរបស់ពួកគេ។ ប៉ុន្តែវាអាចឆ្លងទៅផ្នែកផ្សេងទៀតនៃរាងកាយ។



អង់ទីប៊ីយ៉ូទិចអាចព្យាបាលជំងឺរបេងបាន។

### ជំងឺរបេងមិនងាយចម្លងនោះទេ។



ទាល់តែអ្នកចំណាយពេលច្រើននៅក្បែរមនុស្សដែលកំពុងកើតជំងឺរបេង នោះទើបឆ្លង។

ជំងឺរបេងមិនងាយឆ្លងទេ នៅខាងក្រៅអគារ ព្រោះខ្យល់បក់ទៅមក ហើយពន្លឺព្រះអាទិត្យសម្លាប់បាក់តេរីនោះ។

### ជំងឺរបេងមានពីរដំណាក់កាល។



**មនុស្សដែលមានរោគរបេងដំណាក់កាលសម្ងំ:**

- មានផ្ទុកបាក់តេរីដែលបង្កជំងឺរបេង ប៉ុន្តែមិនទាន់ឈឺ។
- មិនអាចចម្លងជំងឺរបេង។
- គួរតែទទួលការព្យាបាលមុនពេលវិវឌ្ឍទៅជាជំងឺរបេងសកម្ម។



**អ្នកដែលមានជំងឺរបេងសកម្ម:**

- មានផ្ទុកបាក់តេរីដែលបង្កជំងឺរបេង ហើយឈឺ។
- អាចចម្លងជំងឺរបេងតាមរយៈការក្អក កណ្តាស់ សើច ស្រែក ឬច្រៀង។
- ត្រូវតែទទួលការព្យាបាល ដើម្បីចៀសវាងការធ្លាក់ខ្លួនឈឺខ្លាំង និងស្លាប់។

### ជំងឺរបេងមិនឆ្លងនោះទេ នៅពេលដែលមនុស្ស:



ស្លៀកសម្លៀកបំពាក់រួមគ្នា។



ប្រើប្រាស់ចាន ស្លាបព្រាសមរួមគ្នា។



ឱប ថើប ឬរួមភេទ។

### ជំងឺរបេងមិនមែនជាជំងឺដែលទូទៅនោះទេ នៅក្នុងសហរដ្ឋអាមេរិក។



ជំងឺរបេងប្រហែល 30 ករណី កើតមាននៅក្នុងខោនធី Pierce ជារៀងរាល់ឆ្នាំ។

### រោគសញ្ញានៃជំងឺរបេងសកម្ម











- ក្អកចំនួន 3 សប្តាហ៍ ឬយូរជាងនេះ។
- គ្រុនក្តៅ
- អស់កម្លាំង ល្ហិតល្ហៃ
- បែកញើសនៅពេលយប់
- ស្រកទម្ងន់
- ក្អកធ្លាក់ឈាម

### មនុស្សដែលមានហានិភ័យខ្ពស់ប្រឈមនឹងជំងឺរបេង



រស់នៅជាមួយមនុស្សដែលកំពុងកើតជំងឺរបេងសកម្ម។



ធ្វើដំណើរទៅកាន់ ឬកើតនៅកន្លែងដែលជំងឺរបេងគឺជាជំងឺដែលទូទៅ។



មានបញ្ហាសុខភាព។

**ស្វែងយល់បន្ថែមដោយចូលទៅកាន់ tpchd.org/tb.**